ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...២៩៧...សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩

ប្រកាស

ស្តីពី

ការកែសម្រួលអត្រាពន្ធគយ លើមុខទំនិញនាំចូលមួយចំនួន ពាក់ព័ន្ធនឹងឧបករណ៍បរិក្ខារថាមពលកកើតឡើងវិញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងទំនិញបង់ពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ៤៦៥ សហវ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៧
- បានឃើញ ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩ លើលិខិតលេខ ៤៤៨៨ សហវ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់ ដើម្បីជម្រុញការអភិវឌ្ឍអគ្គិសនីការូបនីយកម្មជនបទ

សម្រេច

ប្រការ ១.-

ត្រូវបានកែសម្រួលអត្រាពន្ធគយពីអត្រា សាមសិបប្រាំភាគរយ (៣៥%) មកអត្រា ប្រាំពីរភាគរយ (៧%) ចំពោះមុខទំនិញនាំចូលមួយចំនួននៃតារាងពន្ធគយកម្ពុជាជាធរមានដែលមានលេខសម្គាល់ទីតាំងរង ៨៥០៤.៤០.១១, ៨៥០៤.៤០.១៩, ៨៥០៤.៤០.២០, ៨៥០៤.៤០.៣០, ៨៥០៤.៤០.៤០, ៨៥០៤.៤០.៩០, ៨៥០៧.២០.១០, ៨៥០៧.២០.៩០, ៨៥៤១.៤០.១០, ៨៥៤១.៤០.២០, និងទីតាំងរង ៨៥៤១.៤០.៩០ ។

ប្រការ ២.-

ត្រូវបានកែសម្រួលអត្រាពន្ធគយពីអត្រា ដប់ប្រាំភាគរយ (១៥%)មកអត្រា សូន្យភាគរយ (០%)ចំពោះមុខទំនិញនាំចូលមួយចំនួននៃតារាងពន្ធគយកម្ពុជាជាធរមានដែលមានលេខសម្គាល់ទីតាំងរង ៨៤០៤.១០.១០, ៨៤០៤.១០.២០, ៨៤០៤.២០.០០, ៨៤០៤.៩០.១១, ៨៤០៤.៩០.១៩, ៨៤០៤.៩០.២១, ៨៤០៤.៩០.២៩, ៨៤០៤.៩០.៩០, ៨៤១០.១១.០០, ៨៤១០.១២.០០, ៨៤១០.១៣.០០, ៨៤១០.៩០.០០, ៨៤១៣.១៩.១០, ៨៤១៣.៨១.១០, ៨៤១៦.៣០.០០, ៨៤១៦.៩០.០០, ៨៤១៩.១១.១០, ៨៤១៩.១១.៩០, ៨៤១៩.១៩.១០, ៨៤១៩.១៩.៩០, ៨៥០២.៣១.១០, ៨៥០២.៣១.៩០, ៨៥០២.៣៩.១០, ៨៥០២.៣៩.២០, ៨៥០២.៣៩.៣១, ៨៥០២.៣៩.៣៩, ៨៥០២.៤០.០០ និងទីតាំងរង ៩៤០៥.៤០.៥០ ។

ប្រការ ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤.-

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ